**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០២ សរណន.

រាជធានីភ្នំពេញ.ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩


រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
ទទួល
លេខ 1118
ថ្ងៃទី 01 ខែ 04 ឆ្នាំ 99
ចំពោះ


# សារាចរណែនាំ

## ស្តីពីការជ្រើសរើស និងតែងតាំងមន្ត្រីរាជការស៊ីវិល

*****

កន្លងមករាជរដ្ឋាភិបាលបានពិនិត្យឃើញថា មានក្រសួងស្ថាប័នមួយចំនួន បានធ្វើការជ្រើសរើស និងតែងតាំងមន្ត្រីរាជការក្រោមឱវាទពុំសមស្របទៅតាមគោលការណ៍ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី និងសារាចរលេខ ០១ សរ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាល ។ ចំពោះមុខដើម្បីពង្រឹងការអនុវត្តន៍ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗ ជុំវិញការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល អោយកាន់តែមានប្រសិទ្ធិភាព ដើម្បីសំដៅបន្តរួមចំណែកក្នុងការអនុវត្តន៍ អោយបានជោគជ័យជាស្ថាពរ នូវគោលនយោបាយកំណែទំរង់រដ្ឋបាលសាធារណៈ និងពង្រឹងនីតិរដ្ឋនោះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម :

**១.ការជ្រើសរើស :**

ក្នុងការជ្រើសរើសមន្ត្រីរាជការស៊ីវិល ចូលក្នុងក្របខ័ណ្ឌរដ្ឋ ត្រូវអនុវត្តតាមបញ្ញត្តិដែលមានចែងក្នុងជំពូកទី II នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ជាពិសេសមាត្រា ១៣ បានចែងថា " ជាគោលការណ៍រាល់ការជ្រើសរើសបេក្ខជនអោយចូលក្នុងក្របខ័ណ្ឌ ត្រូវធ្វើឡើងតាមការប្រឡងប្រជែង លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយរាជរដ្ឋាភិបាល "។ បែបបទនៃការជ្រើសរើសនេះមានចែងក្នុងសារាចរ លេខ ០១ សរ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧ ។

**២.ការតែងតាំងមុខតំណែង :**

ជាគោលការណ៍ ការតែងតាំងអោយកាន់មុខតំណែងណាមួយ នៃមុខងារសាធារណៈ របស់ក្រសួងស្ថាប័នត្រូវអនុវត្តចំពោះអ្នករាជការក្របខ័ណ្ឌ នៃក្រសួងស្ថាប័ននោះ ។

ការតែងតាំងនោះត្រូវផ្អែកលើសំណូមពរ ភារកិច្ចជាក់ស្តែង សញ្ញាប័ត្រជំនាញ បទពិសោធន៍ការងារ របស់សាមីជន អោយសមស្របទៅតាមតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ របស់ក្រសួងស្ថាប័ននីមួយៗ ។ ការតែងតាំងអោយកាន់មុខតំណែងណាមួយក្នុងមុខងារសាធារណៈ ត្រូវអនុវត្តអោយបានសមស្របទៅតាមច្បាប់ស្តីពីការរៀបចំ

និងការប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រី ដែលមានចែងជាពិសេស ក្នុងមាត្រា ២៨ ជំពូក III ស្តីពីសិទ្ធិក្នុងការតែងតាំង ។

**៣.ការផ្ទេរ** :

រាល់ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ពីក្រសួងស្ថាប័នមួយ ទៅក្រសួងស្ថាប័នមួយទៀត ជាគោលការណ៍ត្រូវមានការឯកភាពពី រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**៤.ហាមឃាត់** :

**ក**/ តាមស្មារតីខាងលើនេះ មិនត្រូវបានអនុញ្ញាតអោយធ្វើការតែងតាំងមុខតំណែងមុខងារសាធារណៈ ក្នុងករណីដូចខាងក្រោម :

- អ្នកដែលគ្មានឈ្មោះក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ✓
- អ្នកដែលកំពុងបំពេញកម្មសិក្សា ពុំទាន់តាំងស៊ប់ក្នុងក្របខ័ណ្ឌ ។
- ការតែងតាំងថ្នាក់ស្មើ ក្នុងមុខតំណែងណាមួយ ដោយគ្មានក្នុងរចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងស្ថាប័ន ។
- ការតែងតាំងបន្ថែមចំនួនមន្ត្រី ក្នុងមុខតំណែងអនុប្រធាននាយកដ្ឋាន អនុប្រធានការិយាល័យ អនុប្រធានមន្ទីរនៅខេត្ត ក្រុង ក្នុងករណីដែលនាយកដ្ឋាន ការិយាល័យ ឬមន្ទីរនោះ មានអនុប្រធានចាប់ពី ២ នាក់ឡើងទៅរួចហើយ ។ ក្នុងករណីចាំបាច់ត្រូវពិគ្រោះជាមួយ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីពិនិត្យលើរចនាសម្ព័ន្ធជាមុន ។

**ខ**/ ហាមផ្ទេរបញ្ចូលមកក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល នូវមន្ត្រីបុគ្គលិកយោធា - នគរបាលជាតិ បុគ្គលិកស្ថិតក្នុងអង្គភាពម្ចាស់ការហិរញ្ញវត្ថុ ស្វ័យភិបាលសេដ្ឋកិច្ច និងក្របខ័ណ្ឌផ្សេងទៀត ដែលមិនស្ថិតនៅក្រោមច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។ ក្នុងករណីពិសេសត្រូវមានការយល់ព្រមពី រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងទីស្តីការគណៈរដ្ឋមន្ត្រី ។

ទទួលបានសារាចរនេះ រដ្ឋមន្ត្រីគ្រប់ក្រសួង និងរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តតាមខ្លឹមសារខាងលើនេះ ដោយស្មារតីទទួលខុសត្រូវ និង អោយមានប្រសិទ្ធិភាពខ្ពស់ ។

នាយករដ្ឋមន្ត្រី

ហ៊ុន សែន